ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល

សំណុំរឿងព្រហ្មទណ្ឌលេខ ៩៧១អក
ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦
សាលក្រមចាត់របៀបលេខ .013. "ង១"
ចុះថ្ងៃទី.25. ខែឧសភា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការខេត្តកណ្ដាល

បានបើកសវនាការជាសាធារណៈនា ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចខាងក្រោម ៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោកស្រី [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

### ដើម្បីជំនុំជម្រះ

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៧១អក ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦ ដែលមានជនជាប់ចោទ ៖

១- ឈ្មោះ [redacted] សែម ភេទស្រី អាយុ ៣១ឆ្នាំ កើតឆ្នាំ១៩៨៥ ជនជាតិខ្មែរ មុខរបរ កម្មការនីរោងចក្រ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តតាកែវ និងមានឪពុកឈ្មោះ [redacted] ង៉ែត (ស្លាប់) ម្ដាយឈ្មោះ [redacted] តន់ (រស់) ប្ដីឈ្មោះ [redacted] លីឡេង មានកូនចំនួន ០២នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

២. ឈ្មោះ [redacted] សារ៉ាត ភេទស្រី អាយុ ១៧ឆ្នាំ កើតឆ្នាំ១៩៩៩ ជនជាតិខ្មែរ មុខរបរកសិករ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្ដាល មានឪពុកឈ្មោះ [redacted] ម៉េត (រស់) ម្ដាយឈ្មោះ [redacted] យ៉ាវ (រស់) នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ត្រូវដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ **ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ** ប្រព្រឹត្តនៅភូមិតាដោលទី២ ឃុំអំពៅព្រៃ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមមាត្រា ១០ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ។

ដែលលមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉ាវ ភេទស្រី អាយុ ៦០ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិតាដោល២ ឃុំអំពៅព្រៃ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទខាងលើមានដូចតទៅ៖**

កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ នៅចំណុចភូមិតាដោលទី២ ឃុំអំពៅព្រៃ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ឈ្មោះ [redacted] សាវ៉ាត បានភូតកុហកម្ដាយរបស់ខ្លួនឈ្មោះ [redacted] យ៉ាវ ថាទៅធ្វើការនៅរោងចក្រកាត់ដេរម្ដុំឃុំសៀមរាប ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល តែផ្ទុយទៅវិញឈ្មោះ [redacted] សាវ៉ាត ភេទស្រី អាយុ ១៧ឆ្នាំ បានទំនាក់ទំនងជាមួយឈ្មោះ [redacted] សែម ហៅ លីន ដើម្បីទៅយកប្ដីនៅប្រទេសចិនមិនមែនទៅធ្វើការនៅរោងចក្រនោះទេ។ ឈ្មោះ [redacted] សែម ហៅ លីន បាននាំឈ្មោះ [redacted] សាវ៉ាត ទៅជួបនឹងឈ្មោះ សិទ្ធិ ដែលជាបណ្ដាញរបស់ខ្លួន ដើម្បីធ្វើលិខិតឆ្លងដែនទៅប្រទេសចិន។ ពេលទៅដល់ប្រទេសចិនឈ្មោះ [redacted] សាវ៉ាត បានក្លាយជាបណ្ដាញដើរទំនាក់ទំនងជាមួយស្ត្រីផ្សេងទៀត ដើម្បីយកប្ដីទៅប្រទេសចិនដូចខ្លួន និងឈ្មោះ [redacted] សែម ហៅ លីន ផងដែរ ។

- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៧០ដកសស ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ។
- បានឃើញ ដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សែម លេខ: ៦២៨ដក.ចខ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ។
- បានឃើញ ដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សាវ៉ាត លេខ: ៦២៣ដក.ចខ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១០៧២ដកសព ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងខេត្តកណ្ដាល ។
- បានឃើញ ដីកាដំណោះស្រាយលេខ: ១៩៤៣ដកដស ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្ដាល ។

**នាពេលសវនាការ**

១-អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉ាវ បានឆ្លើយថា៖ កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជិត ០៥ភ្លឺ កូនស្រីរបស់ខ្លួនឈ្មោះ [redacted] សាវ៉ាត បានសុំខ្លួនយកសៀវភៅគ្រួសារ និងសំបុត្រកំណើតពីខ្លួន ដើម្បីធ្វើតេស្តចូលធ្វើការនៅរោងចក្រនៅស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល តាមរយៈឈ្មោះ [redacted] វណ្ណា ហៅ ញ៉ាញ់ រហូតដល់វេលាម៉ោង ៦ កូនរបស់ខ្លួន បានត្រលប់មកផ្ទះវិញ ហើយប្រាប់ខ្លួនថាធ្វើតេស្តជាប់ ហើយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ បានរោងចក្រឲ្យចូលធ្វើការ។ រហូតដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ កូនរបស់ខ្លួនបានចេញពីផ្ទះទៅធ្វើការ រហូតដល់ម៉ោង ០៦ ល្ងាចថ្ងៃដដែល ខ្លួនបានឃើញឈ្មោះ [redacted] វណ្ណា ហៅ ញ៉ាញ់ ត្រឡប់មកផ្ទះហើយ ប៉ុន្តែមិនកូនរបស់ខ្លួននោះទេ។ លុះដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង ១២ថ្ងៃត្រង់ កូនរបស់ខ្លួនបានខលមកប្រាប់ថាកូនចាញ់បោកគេហើយ ឥលូវកូននៅប្រទេសចិន និងឲ្យហៅប៉ូលីសមកថតសំលេង បន្ទាប់មកខ្លួនក៏បានទៅដាក់ពាក្យបណ្ដឹងប្ដឹងពីឈ្មោះ [redacted] វណ្ណា ហៅ ញ៉ាញ់ ដែលបាននាំកូនស្រីខ្លួនទៅធ្វើការរោងចក្របាត់ខ្លួន។ នៅថ្ងៃនោះដែលកូនស្រីរបស់ខ្លួនបានឲ្យខ្លួនទៅយកសំបុត្រកំណើត និងសៀវភៅគ្រួសារពីឈ្មោះ [redacted] វណ្ណា ហៅ ញ៉ាញ់ និងប្រាប់ខ្លួនឲ្យបើកលុយរឹងចំនួន ១០០០ ដុល្លារផងដែរ។



Scanned with CamScanner

២-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីមៅ បានឆ្លើយថា៖ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ឈ្មោះ [redacted] យ៉ាវ បានមកប្រាប់ខ្លួនថាឈ្មោះ [redacted] សារ៉ាត បានទៅធ្វើតេស្តជាមួយឈ្មោះ [redacted] វណ្ណា ជាប់ហើយទោះមិនគ្រប់អាយុក៏គេយកដែរ ។ លុះដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១២ថ្ងៃត្រង់ខ្លួនបានលឺអ្នកភូមិខ្លួននិយាយថាក្មួយខ្លួនឈ្មោះ ម៉េត សារ៉ាត ឥឡូវនេះនៅប្រទេសចិន ភ្លាមនោះខ្លួនក៏បានមកជួបឈ្មោះ [redacted] យ៉ាវ នៅផ្ទះពេលមកដល់បងថ្លៃខ្លួនឈ្មោះ [redacted] ម៉េត បានប្រាប់ខ្លួនថាឈ្មោះ [redacted] សារ៉ាត បានទូរស័ព្ទពីប្រទេសចិនមកប្រាប់ថាត្រូវបានឈ្មោះ ស៊ិន វណ្ណា បាននាំទៅជួបមេខ្យល់ យកឈ្មោះ [redacted] សារ៉ាត ទៅយកប្តីនៅប្រទេសចិន និងឱ្យយកសៀវភៅគ្រួសារ និងសំបុត្រកំណើតពីឈ្មោះ [redacted] វណ្ណា បន្ទាប់មកខ្លួនក៏នាំទៅរាយការណ៍ប្រាប់ប៉ូលីសប៉ុស្តិ៍អំពៅព្រៃឱ្យបានដឹង ។ រហូតវេលាម៉ោងប្រហែល ០៣រសៀលថ្ងៃដដែលស្រាប់តែមានមនុស្សប្រុសម្នាក់ បានទូរស័ព្ទមកបងថ្លៃខ្លួន តែបងស្រីខ្លួនជាអ្នកទទួលហើយប្រាប់ថាកុំភ័យចាំពេលល្ងាចម៉ោងប្រហែល ០៥ ថ្ងៃនេះឱ្យឈ្មោះ ញ៉ាញ់ យកសៀវភៅគ្រួសារ និងសំបុត្រកំណើតឱ្យដល់ផ្ទះ និងចាំទៅបើកលុយនៅភ្នាក់ងារវីងចំនួន ១០០០(មួយពាន់)ដុល្លា នៅម្តុំផ្សារសៀមរាប បន្ទាប់មកមនុស្សប្រុសបានប្រាប់ឱ្យខ្លួនមិនបាច់ទៅយកសំបុត្រកំណើត និងសៀវភៅគ្រួសារពីឈ្មោះ ញ៉ាញ់នោះទេ ចាំទៅបើកនៅកន្លែងវីងនោះតែម្តង ។ លុះដល់ថ្ងៃទី១៣ ខែឆ្នាំដដែល វេលាម៉ោងប្រហែល៤រសៀល ខ្លួនបានទូរស័ព្ទទៅក្មួយស្រីឈ្មោះ [redacted] សារ៉ាត នៅប្រទេសចិន ហើយខ្លួនបានសួរឈ្មោះ [redacted] សារ៉ាត ថាហ្វែងទៅដល់ប្រទេសដោយរបៀបណា ពេលនោះឈ្មោះ [redacted] សារ៉ាត បានឆ្លើយថា ឈ្មោះ [redacted] វណ្ណា បាននាំខ្លួនទៅជួបមនុស្សប្រុសម្នាក់ឈ្មោះ ស្វិត ពុំដឹងនៅទីណានោះទេ ជួបនៅការ៉ាសសាំងមួយកន្លែងពុំចាំឈ្មោះក្នុងក្រុងភ្នំពេញបន្ទាប់មកក៏ហៅប៉ូលីសប៉ុស្តិ៍អំពៅព្រៃម្នាក់ឈ្មោះ [redacted] រ៉ា និយាយជាមួយឈ្មោះ [redacted] សារ៉ាត និងថតសម្លេងដាក់ក្នុងទូរស័ព្ទ ។

៣.តាមអំណានចម្លើយឈ្មោះ [redacted] វណ្ណា ហៅញ៉ាញ់ បានឆ្លើយថា៖នៅអំឡុងឆ្នាំ២០១៦ ឈ្មោះ [redacted] យ៉ាវ ត្រូវជាម្តាយរបស់ឈ្មោះ [redacted] សារ៉ាត បានមកជួបខ្លួននៅផ្ទះចំនួន ០៣ដង ដើម្បីសួររកសៀវភៅគ្រួសារ និងលុយដែលកូនគាត់ផ្ញើរមកឱ្យ ហើយខ្លួនបានប្រាប់គាត់វិញថាខ្លួនមិនដែលមានទំនាក់ទំនងអ្វីជាមួយកូនមីងនោះទេ ពេលនោះខ្លួនក៏បានសួរតបទៅគាត់វិញថា មីងឯងដឹងមកពីណាថាមានគេផ្ញើរលុយ និងសៀវភៅគ្រួសារនៅរោងចក្រខ្លួន តែឈ្មោះ [redacted] យ៉ាវ ទៅធ្វើតេស្តនៅរោងចក្រនោះទេ ។ ខ្លួនមិនដែលនាំ ឬបបួលឈ្មោះ ម៉េត សារ៉ាត ដែលជាកូនស្រីរបស់ឈ្មោះ [redacted] យ៉ាវ ទៅធ្វើតេស្តនៅរោងចក្រនោះទេ ។ ហើយខ្លួនក៏មិនដែលដឹងថាឈ្មោះ [redacted] សារ៉ាត ទៅយកប្តីនៅប្រទេសចិនដែរ រហូតទាល់តែមានពាក្យបណ្តឹងរបស់ឈ្មោះ [redacted] យ៉ាវ ទើខ្លួនដឹងថាឈ្មោះ ម៉េត សារ៉ាត នៅប្រទេសចិន ។

៤.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សំអុល បានឆ្លើយថា៖ខ្លួនបានធ្លាប់ឃើញឈ្មោះ [redacted] សារ៉ាត មកជួបជាមួយឈ្មោះ លីន នៅបន្ទប់ជួល នៅជាប់រោងចក្រដែលខ្លួនធ្វើការចំនួន ០២ដង ជួបលើកទី១ នៅចុងខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង ០៧ព្រឹក ពេលខ្លួនមកធ្វើការឈ្មោះ លីន បានខ្ចីម៉ូតូខ្លួនទៅថតរូបដើម្បីធ្វើតេស្តប៉ាសស្ព័រ ពេលឈ្មោះ លីន ជិះចេញទៅឃើញមានមនុស្សស្រីម្នាក់គឺឈ្មោះ [redacted] សារ៉ាត ហើយនៅថ្ងៃពុំចាំមុនទៅប្រទេសចិនមួយថ្ងៃខ្លួនបានឃើញឈ្មោះ [redacted] សារ៉ាត មកជិកជាមួយ

ឈ្មោះ លីន នៅផ្ទះជួល ហើយឈ្មោះ ស៊ិត នឹងក៏មកដែរ ផឹកដល់ម៉ោង ១០យប់ទើបបំបែកគ្នាទៅផ្ទះ ។ ខ្លួនធ្លាប់លឺគេនិយាយថាមនុស្សប្រុសម្នាក់ពុំស្គាល់អត្តសញ្ញាណនៅក្រុងភ្នំពេញធ្លាប់មកជួបឈ្មោះ លីន នៅផ្ទះជួលដើម្បីទំនាក់ទំនងទៅប្រទេសចិន ។ ពេលដែលឈ្មោះ លីន ទៅដល់ប្រទេសចិន បានយកប្តីនៅប្រទេសចិនហើយ ព្រមទាំងទូរស័ព្ទមកខ្លួនតាមរយៈលេខទូរស័ព្ទលេខ+៨៦១៥១៧៩៨៥៦០២៩ មកលេងខ្លួន ដើម្បីនិយាយគ្នាលេង ហើយឈ្មោះ លីន បានប្រាប់ខ្លួនថាឈ្មោះ សិទ្ធិ ភេទប្រុស អាយុ ២៧ឆ្នាំ រស់នៅម្តុំបឹងត្របែក ក្រុងភ្នំពេញ ប្រើលេខទូរស័ព្ទ០៩៨៧២៨៦៣៨ ជាអ្នកនាំខ្លួន និងឈ្មោះ [redacted] សារ៉ាត ទៅប្រទេសចិន ។

៤-តំណាងអយ្យការសន្និដ្ឋាន ៖ តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមអំណានចម្លើយសាក្សី និងភស្តុតាងនានាបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] សែម ហៅលីន និងឈ្មោះ [redacted] សារ៉ាត ត្រូវជាប់ចោទពីបទៈ **ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ដូច្នេះប្តឹងសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមកំណត់ច្បាប់ ។

៥-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សែម និងជនជាប់ចោទឈ្មោះ [redacted] សារ៉ាត បានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានសិក្សាសំណុំរឿង ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ និងក្រោយពីស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ខ្លួនបានសង្កេតឃើញថា ជនជាប់ចោទពុំបានប្រព្រឹត្តអំពើដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ។

## យល់ឃើញថា

១-តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉ាវ បានឆ្លើយថាៈ កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជិត ០៥ភ្លឺ កូនស្រីរបស់ខ្លួនឈ្មោះ [redacted] សារ៉ាត បានសុំខ្លួនយកសៀវភៅគ្រួសារ និងសំបុត្រកំណើតពីខ្លួន ដើម្បីធ្វើតេស្តចូលធ្វើការនៅរោងចក្រនៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល តាមរយៈឈ្មោះ [redacted] វណ្ណា ហៅ ញ៉ាញ់ រហូតដល់វេលាម៉ោង ៦ កូនរបស់ខ្លួន បានត្រលប់មកផ្ទះវិញ ហើយប្រាប់ខ្លួនថាធ្វើតេស្តជាប់ ហើយនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ បានរោងចក្រឲ្យចូលធ្វើការ។ រហូតដល់ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ កូនរបស់ខ្លួនបានចេញពីផ្ទះទៅធ្វើការ រហូតដល់ម៉ោង ០៦ ល្ងាចថ្ងៃដដែល ខ្លួនបានឃើញឈ្មោះ [redacted] វណ្ណា ហៅ ញ៉ាញ់ ត្រឡប់មកផ្ទះហើយ ប៉ុន្តែមិនកូនរបស់ខ្លួននោះទេ។ លុះដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង ១២ថ្ងៃត្រង់ កូនរបស់ខ្លួនបានខលមកប្រាប់ថាកូនចាញ់បោកគេហើយ ឥលូវកូននៅប្រទេសចិន និងឲ្យហៅប៉ូលីសមកថតសំលេង បន្ទាប់មកខ្លួនក៏បានទៅដាក់ពាក្យបណ្តឹងប្តឹងពីឈ្មោះ [redacted] វណ្ណា ហៅ ញ៉ាញ់ ដែលបាននាំកូនស្រីខ្លួនទៅធ្វើការរោងចក្របាត់ខ្លួន។ នៅថ្ងៃនោះដែលកូនស្រីរបស់ខ្លួនបានឲ្យខ្លួនទៅយកសំបុត្រកំណើត និងសៀវភៅគ្រួសារពីឈ្មោះ [redacted] វណ្ណា ហៅ ញ៉ាញ់ និងប្រាប់ខ្លួនឲ្យបើកលុយរៀងចំនួន ១០០០ ដុល្លារផងដែរ។

២-តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីមៅ បានឆ្លើយថាៈ កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ឈ្មោះ [redacted] យ៉ាវ បានមកប្រាប់ខ្លួនថាឈ្មោះ [redacted] សារ៉ាត បានទៅធ្វើតេស្តជាមួយឈ្មោះ ស៊ិន វណ្ណា ជាប់ហើយទោះមិនគ្រប់អាយុក៏គេយកដែរ ។ លុះដល់ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោងប្រហែល ១២ថ្ងៃត្រង់ខ្លួនបានលឺអ្នកភូមិខ្លួននិយាយថាក្មួយខ្លួនឈ្មោះ [redacted] សារ៉ាត ឥឡូវនេះនៅប្រទេសចិន ភ្លាមនោះខ្លួនក៏បានមកជួបឈ្មោះ [redacted] យ៉ាវ នៅផ្ទះពេលមកដល់បងថ្លៃខ្លួនឈ្មោះ [redacted] ម៉េត បាន

ប្រាប់ខ្លួនថាឈ្មោះ [redacted] សារ៉ាត បានទូរស័ព្ទពីប្រទេសចិនមកប្រាប់ថាត្រូវបានឈ្មោះ [redacted] វណ្ណា បាននាំទៅជួបមេខ្យល់ យកឈ្មោះ [redacted] សារ៉ាត ទៅយកប្តីនៅប្រទេសចិន និងឱ្យយកសៀវភៅគ្រួសារ និងសំបុត្រកំណើតពីឈ្មោះ [redacted] វណ្ណា បន្ទាប់មកខ្លួនក៏នាំទៅរាយការណ៍ប្រាប់ប៉ូលីសប៉ុស្តិ៍អំពៅព្រៃឱ្យបានដឹង ។ រហូតវេលាម៉ោងប្រហែល ០៣រសៀលថ្ងៃដដែលស្រាប់តែមានមនុស្សប្រុសម្នាក់ បានទូរស័ព្ទមកបងថ្លៃខ្លួន តែបងស្រីខ្លួនជាអ្នកទទួលហើយប្រាប់ថាកុំភ័យចាំពេលល្ងាចម៉ោងប្រហែល ០៥ ថ្ងៃនេះឱ្យឈ្មោះ ញ៉ាញ់ យកសៀវភៅគ្រួសារ និងសំបុត្រកំណើតឱ្យដល់ផ្ទះ និងចាំទៅបើកលុយនៅភ្នាក់ងារវីងចំនួន ១០០០(មួយពាន់)ដុល្លា នៅម្តុំផ្សារសៀមរាប បន្ទាប់មកមនុស្សប្រុសបានប្រាប់ឱ្យខ្លួនមិនបាច់ទៅយកសំបុត្រកំណើត និងសៀវភៅគ្រួសារពីឈ្មោះ ញ៉ាញ់នោះទេ ចាំទៅបើកនៅកន្លែងវីងនោះតែម្តង ។ លុះដល់ថ្ងៃទី១៣ ខែឆ្នាំដដែល វេលាម៉ោងប្រហែល៤រសៀល ខ្លួនបានទូរស័ព្ទទៅក្មួយស្រីឈ្មោះ [redacted] សារ៉ាត នៅប្រទេសចិន ហើយខ្លួនបានសួរឈ្មោះ [redacted] សារ៉ាត ថាហ្វេងទៅដល់ប្រទេសដោយរបៀបណា ពេលនោះឈ្មោះ [redacted] សារ៉ាត បានឆ្លើយថា ឈ្មោះ ស៊ុន វណ្ណា បាននាំខ្លួនទៅជួបមនុស្សប្រុសម្នាក់ឈ្មោះ ស្វិត ពុំដឹងនៅទីណានោះទេ ជួបនៅកាហ្វេសសាំងមួយកន្លែងពុំចាំឈ្មោះក្នុងក្រុងភ្នំពេញបន្ទាប់មកក៏ហៅប៉ូលីសប៉ុស្តិ៍អំពៅព្រៃម្នាក់ឈ្មោះ [redacted] និយាយជាមួយឈ្មោះ [redacted] សារ៉ាត និងថតសម្លេងដាក់ក្នុងទូរស័ព្ទ ។

៣.តាមអំណានចម្លើយឈ្មោះ [redacted] វណ្ណា ហៅញ៉ាញ់ បានឆ្លើយថា៖នៅអំឡុងឆ្នាំ២០១៦ ឈ្មោះ [redacted] យ៉ាវ ត្រូវជាម្តាយរបស់ឈ្មោះ [redacted] សារ៉ាត បានមកជួបខ្លួននៅផ្ទះចំនួន ០៣ដង ដើម្បីសួររកសៀវភៅគ្រួសារ និងលុយដែលកូនគាត់ផ្ញើរមកឱ្យ ហើយខ្លួនបានប្រាប់គាត់វិញថាខ្លួនមិនដែលមានទំនាក់ទំនងអ្វីជាមួយកូនមីងនោះទេ ពេលនោះខ្លួនក៏បានសួរតបទៅគាត់វិញថា មីងឯងដឹងមកពីណាថាមានគេផ្ញើរលុយ និងសៀវភៅគ្រួសារនៅរោងចក្រខ្លួន តែឈ្មោះ [redacted] យ៉ាវ ទៅធ្វើតេស្តនៅរោងចក្រនោះទេ ។ ខ្លួនមិនដែលនាំ ឬបបួលឈ្មោះ ម៉េត សារ៉ាត ដែលជាកូនស្រីរបស់ឈ្មោ [redacted] យ៉ាវ ទៅធ្វើតេស្តនៅរោងចក្រនោះទេ ។ ហើយខ្លួនក៏មិនដែលដឹងថាឈ្មោះ [redacted] សារ៉ាត ទៅយកប្តីនៅប្រទេសចិនដែរ រហូតទាល់តែមានពាក្យបណ្តឹងរបស់ឈ្មោះ [redacted] យ៉ាវ ទើខ្លួនដឹងថាឈ្មោះ [redacted] សារ៉ាត នៅប្រទេសចិន ។

៤.តាមអំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សំអុល បានឆ្លើយថា៖ខ្លួនបានធ្លាប់ឃើញឈ្មោះ ម៉េត សារ៉ាត មកជួបជាមួយឈ្មោះ លីន នៅបន្ទប់ជួល នៅជាប់រោងចក្រដែលខ្លួនធ្វើការចំនួន ០២ដង ជួបលើកទី១ នៅចុងខែមិថុនា ឆ្នាំ២០១៦ វេលាម៉ោង ០៧ព្រឹក ពេលខ្លួនមកធ្វើការឈ្មោះ លីន បានខ្ចីម៉ូតូខ្លួនទៅថតរូបដើម្បីធ្វើតេស្តប៉ាសស្ព័រ ពេលឈ្មោះ លីន ជិះចេញទៅឃើញមានមនុស្សស្រីម្នាក់គឺឈ្មោះ ម៉េត សារ៉ាត ហើយនៅថ្ងៃពុំចាំមុនទៅប្រទេសចិនមួយថ្ងៃខ្លួនបានឃើញឈ្មោះ [redacted] សារ៉ាត មកផឹកជាមួយឈ្មោះ លីន នៅផ្ទះជួល ហើយឈ្មោះ ស្វិត នឹងក៏មកដែរ ផឹកដល់ម៉ោង ១០យប់ទើបបំបែកគ្នាទៅផ្ទះ ។ ខ្លួនធ្លាប់លឺគេនិយាយថាមនុស្សប្រុសម្នាក់ពុំស្គាល់អត្តសញ្ញាណនៅក្រុងភ្នំពេញធ្លាប់មកជួបឈ្មោះ លីន នៅផ្ទះជួលដើម្បីទំនាក់ទំនងទៅប្រទេសចិន ។ ពេលដែលឈ្មោះ លីន ទៅដល់ប្រទេសចិន បានយកប្តីនៅប្រទេសចិនហើយ ព្រមទាំងទូរស័ព្ទមកខ្លួនតាមរយៈលេខទូរស័ព្ទលេខ+៨៦១៥១៧៩៨៥៦០២៩ មកលេងខ្លួន ដើម្បីនិយាយគ្នាលេង ហើយឈ្មោះ លីន បានប្រាប់ខ្លួនថាឈ្មោះ សិទ្ធិ ភេទប្រុស អាយុ ២៧ឆ្នាំ រស់



Scanned with CamScanner

នៅម្តុំបឹងត្របែក ក្រុងភ្នំពេញ ប្រើលេខទូរស័ព្ទ០៩៨៧២៤៦៣៤ ជាអ្នកនាំខ្លួន និងឈ្មោះ [redacted] សារ៉ាត ទៅប្រទេសចិន ។

៥-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបង្ហាញឱ្យឃើញ ៖ជនជាប់ចោទឈ្មោះ [redacted] សែម ហៅលីន និងឈ្មោះ [redacted] សារ៉ាត ពិតជាបានប្រព្រឹត្តអំពើ៖ ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ បទល្មើសព្រហ្មទណ្ឌមានកំណត់ឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ដូច្នេះប្តឹងសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមកំណត់ច្បាប់ ប្រាកដមែន។ ស្របតាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ។

៦.តាមសេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សែម និងជនជាប់ចោទឈ្មោះ [redacted] សារ៉ាត បង្ហាញឱ្យឃើញថា៖ កូនក្តីរបស់ខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ខ្លួនស្នើសុំតុលាការលើកលែងការចោទប្រកាន់ ។

៧.ចៅក្រមស៊ើបសួរពុំបានធ្វើការស៊ើបសួរលើជនសង្ស័យឈ្មោះ [redacted] វណ្ណា ហៅញ៉ាញ់ ដូច្នេះតុលាការពុំអាចវាយតម្លៃសន្និដ្ឋានផ្តន្ទាទោសលើជនជាប់ចោទបានឡើយ គប្បីចាត់របៀបលើសំណុំរឿងនេះ ដើម្បីបើកការស៊ើបសួរលើជនសង្ស័យឈ្មោះ [redacted] វណ្ណា ហៅញ៉ាញ់ ឱ្យបានច្បាស់លាស់ជាមូលដ្ឋានផ្តន្ទាទោស ។

## ហេតុដូច្នេះសម្រេច

១- ចាត់របៀបលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៧១អក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ដើម្បីស៊ើបសួរបន្ថែមលើជនសង្ស័យឈ្មោះ [redacted] វណ្ណា ហៅញ៉ាញ់ ។

២- ចាត់តាំងលោក [redacted] ដើម្បីស៊ើបសួរបន្ថែម ។

៣- សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សែម,ឈ្មោះ [redacted] សារ៉ាត និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] យ៉ារ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សា**

ត្ថលេខា និងត្រា [redacted]

**តំណាងអយ្យការ**

ហត្ថលេខា និងត្រា ខា ដែនណា

ថ្ងៃពុធ ៧រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កណ្តាល,ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner